114/8

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ៥៤ "ក្រ៨ង"

-ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨

-សំណុំរឿងព្រហ្មទណ្ឌលេខ១៣៤៨

ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៧

បានបើកសវនាការជាសាធារណៈនាថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៧ វេលាម៉ោង ០២:០០ នាទីរសៀល នៅសាលសវនាការទី៤ ដោយមានសមាសភាពដូចខាងក្រោម ៖

### ចៅក្រមជំនុំជម្រះ

លោកចៅក្រម [redacted] ជាប្រធានក្រុមប្រឹក្សា

លោកចៅក្រម [redacted] ជាចៅក្រមក្រុមប្រឹក្សា

លោកចៅក្រម [redacted] ជាចៅក្រមក្រុមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ ១៣៤៨ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៧ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] សុផល ភេទប្រុស អាយុ៤៥ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ ប៉ូលីសខេត្តស្ទឹងត្រែង ទីកន្លែងកំណើតភូមិត្រពាំងព្រីង ឃុំស្ទឹងត្រែង ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] (រស់) មានកូន០៤នាក់ ជានីតិជន ទោសពីមុនគ្មាន។

ឃាត់ខ្លួនថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៧ ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ១១៧ ង.ស ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៧។

២-ឈ្មោះ [redacted] ម៉ូរ៉ា ហៅគ័ត្រ ភេទប្រុស អាយុ ៣២ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិភូមិត្រពាំងព្រីង សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ជានីតិជន។ (គេចខ្លួន)

មានលោក [redacted] យ៉េត និងលោក [redacted] ម៉ូរ៉េល ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សុផល។

114
7

មានលោក[redacted]គាន់អៀម ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]បូរ៉ា។

**<u>អង្គហេតុនៃរឿងមានដូចតទៅ</u>**

កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ឈ្មោះ[redacted]បូរ៉ា ហៅភ័ក្ត្រ ភេទប្រុស អាយុ៣២ឆ្នាំ ត្រូវជាក្មួយរបស់ឈ្មោះ[redacted]សុផល ភេទប្រុស អាយុ៤៥ឆ្នាំ បានមកប្រាប់ឈ្មោះ[redacted]សុផល ថាមានគេនៅប៉ោយប៉ែតជាថៅកែស៊ីម៉ង់ ឧស្សាហ៍ចេញចូលប្រទេសថៃ គេចង់បានគ្រឿងញៀនប្រភេទគ្រាប់ ពេលនោះឈ្មោះ[redacted]សុផល បានឆ្លើយថាចាំខ្លួនទៅទំនាក់ទំនងគេឱ្យ។ លុះដល់ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៧ វេលាម៉ោងប្រហែល៩ព្រឹក ឈ្មោះ[redacted]សុផល បានជិះឡានទៅប្រទេសឡាវដើម្បីជួបឈ្មោះ វិល័យ ភេទប្រុស ជនជាតិឡាវ ដោយប្រាប់ថាគេមានរកទិញគ្រឿងញៀនប្រភេទគ្រាប់ ពេលនោះឈ្មោះ វិល័យ (មិនស្គាល់អត្តសញ្ញាណ) សួរថាអ្នកទិញគេនៅឯណា បន្ទាប់មកឈ្មោះ[redacted]សុផល ក៏បានយកលេខទូរស័ព្ទគឺលេខ(០២០៩៦៨៨៨៨៦) យកមកឱ្យឈ្មោះ ភ័ក្ត្រ ដើម្បីធ្វើការទំនាក់ទំនងក្នុងការទិញលក់គ្រឿងញៀន។ លុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧ វេលាម៉ោងប្រហែល០៦ល្ងាច ឈ្មោះ ភ័ក្ត្រ បានទូរស័ព្ទទៅឈ្មោះ[redacted]សុផល ថាស្អែកគេឡើងមកយកឥវ៉ាន់ហើយ (គ្រឿងញៀន) ហើយឈ្មោះ[redacted]សុផល ក៏បានសួរទៅឈ្មោះ ភ័ក្ត្រ ថាឥវ៉ាន់នឹងគេឡើងយកមកហើយឬនៅឈ្មោះ ភ័ក្ត្រ ឆ្លើយថាគេបានយកមកឱ្យរួចហើយ ហើយវាបានទុកនៅចំការស្រែសំគុង ឃុំឬស្សីស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង បន្ទាប់មកឈ្មោះ ភ័ក្ត្រ ក៏បាននាំឈ្មោះ[redacted]សុផល ក៏ត្រឡប់មកផ្ទះមកវិញ។ ហើយនៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ វេលាម៉ោងប្រហែល៧ព្រឹក ឈ្មោះភ័ក្ត្រ បានទូរស័ព្ទមកប្រាប់ឈ្មោះ[redacted]សុផល ថានៅវេលាម៉ោង១០ព្រឹកនេះ គេចេញមកយកឥវ៉ាន់ហើយ បន្ទាប់មកឈ្មោះ ភ័ក្ត្រ បាននិយាយទៀតថា ពេលមានម៉ូយមកដល់គេនឹងនាំម៉ូយចូលទៅដល់ចំការ ហើយបើម៉ូយគេមិនហ៊ានចូលទៅទេ ពូឯងជួយយកគ្រឿងញៀនឱ្យគេផង នៅវេលាម៉ោងប្រហែល៩ព្រឹក នាថ្ងៃខែឆ្នាំដដែល ឈ្មោះ[redacted]សុផល ក៏បានបើកឡានចូលទៅក្នុងចំការខាងលើ ពេលនោះឈ្មោះ ភ័ក្ត្រ ក៏បានទូរស័ព្ទមកម្តងទៀតហើយប្រាប់ថា ម៉ូយអ្នកទិញមកដល់ហើយ ប៉ុន្តែគេមិនហ៊ានចូលទៅក្នុងចំការទេ ហើយពេលនោះឈ្មោះ[redacted]សុផល សួរទៅឈ្មោះ ភ័ក្ត្រ ថាតើគិតយ៉ាងម៉េច បន្ទាប់មកឈ្មោះ ភ័ក្ត្រ ប្រាប់ទៅឈ្មោះ[redacted]សុផល ថាឱ្យយកឱ្យគេនៅច្រកផ្លូវចូលទៅចំការប្រហែល៥០ម៉ែត្រពីផ្លូវ ឮដូចនេះឈ្មោះ[redacted]សុផល ក៏បានយកគ្រឿងញៀនទៅដាក់ក្នុងឡានរួចក៏បើកឡានចេញក្រៅ ពេលមកដល់ឈ្មោះ[redacted]សុផល ក៏បានឈប់ឡានប្រហែល១៥ម៉ែត្រ ពីឡានអ្នកទិញ ហើយឈ្មោះ ភ័ក្ត្រ ក៏បានចូលទៅក្នុងឡានរបស់ឈ្មោះ[redacted]សុផល រួចក៏បានយកគ្រឿងញៀនចូលទៅក្នុងឡានរបស់អ្នកទិញ ប្រហែល១៥នាទីក្រោយមក ក៏ឃើញមានមនុស្សប្រុសម្នាក់ចេញពីក្នុងឡានព្រុសមកបាញ់បំបែកកង់ឡានរបស់ឈ្មោះ[redacted]សុផល ខាងមុខផ្នែកខាងឆ្វេង ហើយភ្ជង់ឈ្មោះ[redacted]សុផល ឱ្យក្រាបទៅនឹងដី រួចក៏បានធ្វើការចាប់ឃាត់ខ្លួនរួចឆែកឆេររកឃើញមាននិងបានធ្វើការដកហូតវត្ថុតាងមានថ្នាំញៀនប្រភេទមេតំហ្វេមីន (WY)، ចំនួន២៤000គ្រាប់ ទម្ងន់សរុប២.១៣៤,៥ក្រាម រថយន្តមួយគ្រឿង និងកាំភ្លើងមួយដើម ម៉ាកកា៥៩ លេខ៥៤៨៦ រួចបញ្ជូនមកការិយាល័យគ្រឿងញៀន ដើម្បីធ្វើការសាកសួរ និងចាត់ការនីតិវិធីច្បាប់តែម្តង។ -

-បានឃើញ របាយការណ៍សំយោគលេខ០៧៨/១៧ របក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ២០៧០ អ.យ.ម ចុះថ្ងៃទី០៨ ខែ មិថុនា ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខៈ ២២៦៦ "ណរ"ម.ដ ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

<u>**នាពេលសវនាការ**</u>

-ជនជាប់ចោទឈ្មោះ [redacted] សុផល បានឆ្លើយសារភាពថា៖ ខ្លួនដឹងបទហើយ គឺបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងកាន់កាប់ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត។ ចំពោះបទចោទនេះខ្លួនសុំបដិសេធ ពីព្រោះខ្លួនមិនបានប្រព្រឹត្តដូចតំណាងអយ្យការចោទឡើយ។ ខ្លួនបានធ្វើការជាប៉ូលីសខេត្តស្ទឹងត្រែងមែន ហើយអង្គហេតុឈ្មោះ [redacted] បូរ៉ា បានប្រាប់ថាគេចង់បានគ្រឿងញៀនមែន ប៉ុន្តែខ្លួនមិនបានរកថ្នាំញៀនឱ្យឈ្មោះ [redacted] បូរ៉ា ទេ រីឯឈ្មោះឈ្មោះ វិល័យ នៅប្រទេសឡាវ ខ្លួនធ្លាប់ស្គាល់ដែរ។ ចំពោះស្បោងផង់នេះ ខ្លួនជាអ្នកយួរស្បោងនេះមកដាក់ឡានមែន ប៉ុន្តែខ្លួនមិនបានដឹងថាក្នុងស្បោងនេះមានថ្នាំញៀនទេ បើដឹងថាក្នុងផង់នោះមានថ្នាំញៀនក៏ខ្លួនមិនយួរមកដាក់ឡានដែរ។ មូលហេតុដែលខ្លួនទៅចំការនេះ ពីព្រោះចំការនេះជារបស់ខ្លួនទុកសម្រាប់ចិញ្ចឹមត្រី។ ចំពោះស្បោងផង់នេះពេលដែលខ្លួនយកមកគ្មានអ្វីទេ។ <u>នៅពេលនោះ មានឡានមួយព្រុសចេញមកបាញ់កង់ឡានខ្លួន រួចភ្ជង់ខ្លួនឱ្យក្រាបចុះស្រាប់តែងើបឡើងថាផង់នេះជារបស់ខ្លួន</u>មានថ្នាំញៀនទៅវិញ។ នៅពេលដែលសមត្ថកិច្ចចាប់ឃាត់ខ្លួន ឈ្មោះ ភ័ក្ត្រ ក៏រត់ទៅបាត់មិនដឹងទៅណាទេ។ ខ្លួននិងឈ្មោះ ភ័ក្ត្រ ត្រូវជាពូនិងក្មួយ។ ខ្លួនមានអាវុធម៉ាក k៥៩ មានលិខិតប្រើប្រាស់ស្របច្បាប់។ នៅសមត្ថកិច្ចតំណាងអយ្យការ និងនៅក្រមស៊ើបសួរ ខ្លួនសុំមិនទទួលស្គាល់ទេសុំបដិសេធ។ ខ្លួនសុំបញ្ជាក់ថា ផង់នេះមិនមែនពណ៌ខ្មៅទេ គឺពណ៌ទឹកក្រូច ចំពោះផង់នេះឈ្មោះ ភ័ក្ត្រ បានប្រើខ្លួនឱ្យជួយយកឱ្យវាមែន។ ការសាកសួរនៅដំណាក់កាលសមត្ថកិច្ច ,តំណាងអយ្យការ,នៅចៅក្រមស៊ើបសួរពុំមានពីណាបង្ខិតបង្ខំឱ្យឆ្លើយឡើយ។ ខ្លួនសុំបដិសេធថា មិនបានចូលរួមប្រព្រឹត្តបទល្មើសជាមួយឈ្មោះ ភ័ក្ត្រ ទេ។ នៅពេលខ្លួនឆ្លើយសារភាពថា៖ ចំពោះអង្គហេតុជួញដូរថ្នាំញៀនខ្លួនពិតជាបានប្រព្រឹត្តមែន។ ប៉ុន្តែខ្លួនមិនបានដឹងថាថ្នាំញៀនមានក្នុងផង់នោះទេ។

-សមត្ថកិច្ចនគបាលលោក [redacted] បញ្ញាវិទ្ធ៖ បានរៀបរាប់ថា អង្គហេតុនេះពិតជាត្រឹមត្រូវ ពីព្រោះខ្លួនជាអ្នកដឹកនាំប្រតិបត្តិការនេះផ្ទាល់ ដោយដំបូងពួកខ្លួនបានធ្វើការទំនាក់ទំនងទៅឈ្មោះ ភ័ក្ត្រ ហើយឈ្មោះ ភ័ក្ត្រ ប្រាប់ថាពូគេឈ្មោះ [redacted] សុផល មានគ្រឿងញៀន ទើបពួកខ្លួនបើប្រតិបត្តិការតែម្តង។ នៅពេលនោះឈ្មោះ [redacted] សុផល បានប្រាប់ថាមានថ្នាំញៀននៅចំការ ពេលនោះខ្លួនបានឆ្លងយោបល់មកថ្នាក់លើ ហើយថ្នាក់លើមិនឱ្យចូលចំការទេ ពីព្រោះពួកខ្លួនមានប្រាក់ដុល្លារអាមេរិកច្រើនដើម្បីទុកសម្រាប់ទិញថ្នាំញៀន។ ចំពោះឈ្មោះ ភ័ក្ត្រ មិនជាកម្លាំងបង្កប់របស់សមត្ថកិច្ចនោះទេ រីឯឡានចុះប្រតិបត្តិមានបីឡាន។

-អំណានដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ០១១ពស ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តស្ទឹងត្រែង។

-អំណានកំណត់ហេតុធ្វើតេស្ត៍ និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ របស់ការិយាល័យប្រឆាំងគ្រឿងញៀននៃស្នងការដ្ឋាននគរខេត្តស្ទឹងត្រែង ។

-អំណានលទ្ធផលកោសលវិច័យគ្រឿងញៀន ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៧ របស់មន្ទីរពិសោធន៍នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

114/5

## សេចក្តីសន្និដ្ឋានផ្ទឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទនៅពេលសវនាការ, ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទនៅដំណាក់កាលសមត្ថកិច្ច,ដំណាក់កាលតំណាងអយ្យការ និងដំណាងកាលចៅក្រមស៊ើបសួរនៅខេត្តស្ទឹងត្រែង និងស្តាប់ចម្លើយនៅដំណាក់អយ្យការសាលាដំបូងរាជធានីភ្នំពេញ និងបានពិនិត្យឯកសារក្នុងសំណុំរឿង ដូចនេះតំណាងអយ្យការយល់ឃើញថា ឆ្លងតាមអង្គសវនាការនាពេលឃើញថា ដំបូងឡើយជនជាប់ចោទបានបដិសេធថាខ្លួនមិនបានចូលរួមសកម្មភាពក្នុងអង្គហេតុដែលបានបញ្ជូនមកជំនុំជម្រះដោយចៅក្រមស៊ើបសួរឡើយ ប៉ុន្តែចុងក្រោយជនជាប់ចោទបានឆ្លើយសារភាពជាក់ស្តែងហាក់ដូចជាមិនច្បាស់លាស់ដដែល ប៉ុន្តែជនជាប់ចោទបានឆ្លើយសារភាពនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៍,ដំកាលអយ្យការនិងនៅចៅក្រមស៊ើបសួរសាលាដំបូងខេត្តស្ទឹងត្រែង បានសារភាពថាសុំទទួលស្គាល់ថាខ្លួនបានសហការជាមួយឈ្មោះ [redacted] បូរ៉ា ក្នុងការរកស៊ីទិញថ្នាំញៀនពីប្រទេសឡាវ តាមកំណត់ហេតុទាំងនេះនៅមានតម្លៃជាភស្តុតាង ព្រោះថាជនជាប់ចោទគ្រាន់តែបដិសេធ ពុំមានភស្តុតាងណាមួយដើម្បីយកមកលុបលាងកំណត់ហេតុនេះឡើយ ហើយកំណត់ហេតុនេះនៅមានតម្លៃធ្វើជាភស្តុតាងនៅឡើយ ហើយភស្តុតាងនេះមានភាពស៊ីសង្វាក់ទៅនឹងការបញ្ជាក់របស់មន្ត្រីនគរបាលយុត្តិធម៌ ដែលចុះបង្ក្រាបផ្ទាល់គឺថាការឈានទៅឃាត់ខ្លួនរបស់ជនជាប់ចោទឈ្មោះ [redacted] សុផល តាមវិធានញ៉ុះញ៉ង់គឺតាមមធ្យោបាយជាក់ស្តែង ហើយឃើញថាតាមកំណត់ហេតុចាប់យក វត្ថុតាងនៅពេលចាប់ឃាត់ខ្លួនជាក់ស្តែងក៏ដកបានថ្នាំញៀនដែរ ហើយផ្អែកតាមភស្តុតាងនិងចម្លើយសារភាពរបស់ជនជាប់ចោទនៅខេត្តស្ទឹងត្រែងទាំងអស់ ពិតជាបានចូលរួមប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀនពិតប្រាកដមែន។ ហើយឃើញថាថ្នាំញៀនដែលដកហូតពីជនជាប់ចោទតាមលទ្ធផលកោសលវិច័យគ្រឿងញៀនបញ្ជាក់ថា ប្រភេទមេតំហ្វេតាមីនស្ថិតនៅតារាងទី២ នៃច្បាប់ត្រួតពិនិត្យគ្រឿងញៀន ហើយតាមកំណត់ហេតុចាប់យកវត្ថុតាងថ្នាំញៀន ដែលដកហូតបានពីជនជាប់ចោទមាន២៤០០០គ្រាប់ ស្មើនឹងទម្ងន់២១៣៤,៥ក្រាម ហើយលទ្ធផលកោសលវិច័យឃើញថាមានបរិមាណធាតុសុទ្ធ១៥,១២% ឃើញថាបរិមាណធាតុគុណចែករួចមានចំនួន៣២២,៧៣៦ក្រាម ដូច្នេះឃើញថា បរិមាណធាតុសុទ្ធវាស្ថិតនៅកថាខណ្ឌទី៧ ចំណុចទី៤នៃមាត្រា៤០ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដូចនេះ តំណាងអយ្យការយល់ឃើញថាជនជាប់ឈ្មោះ [redacted] បូរ៉ា និងឈ្មោះ [redacted] សុផល ពិតជាបានប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន ហើយអំពើនេះជាអំពើល្មើសច្បាប់មានចែងមាត្រា៤០ កថាខណ្ឌទី៧ ចំណុចទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន រីឯអង្គហេតុប្រើប្រាស់អាវុធជាតិផ្ទុះឃើញថានៅពេលសវនាការជនជាប់ចោទបានទទួលស្គាល់ថាអាវុធខ្លីនេះជារបស់ខ្លួន ប៉ុន្តែខ្លួនមានឯកសារគ្រប់គ្រាន់តាមការបញ្ជាក់របស់ជនជាប់ចោទ នេះឃើញថាមានតែលិខិតស្នាមជារបស់អង្គភាព ដូច្នេះរបស់អង្គភាពឯកជនមិនអាចយកមកប្រើប្រាស់បានឡើយ លុះត្រាតែមានលិខិតបេសកម្មអនុញ្ញាតឲ្យប្រើប្រាស់ជាក់ស្តែងនៅពេលសវនាការជនជាប់ចោទ ពុំមានលិខិតបេសកម្មអនុញ្ញាតឲ្យប្រើប្រាស់ទេ ដូចនេះជនជាប់ចោទបានប្រព្រឹត្តបទល្មើស ប្រើប្រាស់អាវុធដោយគ្មានការអនុញ្ញាត មានចែងក្នុងមាត្រា៤៩០ នៃ ក្រមព្រហ្មទណ្ឌដូច្នេះសរុបសេចក្តីមកតំណាងអយ្យការស្នើសុំឲ្យផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុផល ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុគ្រឿងញៀន និងកាន់កាប់ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាតតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននិងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

លោកមេធាវី [redacted] ម៉ូរ៉ែល ជាមេធាវីការពារសិទ្ធិឲ្យឈ្មោះ [redacted] សុផល បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ កូនក្តីខ្លួនបានសារភាពគ្រប់ដំណាក់នីតិវិធីថា ខ្លួនពិតជាបានប្រព្រឹត្តបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន

ប្រាកដមែន ដូច្នេះខ្លួនស្នើសុំឱ្យតុលាការបន្ថយបន្ធូរទោសដល់កូនក្តីខ្លួនដោយក្តីអនុគ្រោះផង។ ចំពោះអង្គហេតុអាវុធកូនក្តីខ្លួនមានប័ណ្ណសម្គាល់កាន់កាប់អាវុធនៅមានសុពលភាពរហូតដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៨ ចំពោះលិខិតបេសកម្មវិញកូនក្តីខ្លួនក៏បជាប់ប័ណ្ណកាំភ្លើងតែម្តង នៅពេលគេចាប់ឃាត់ខ្លួនគេដកហូតយកមិនបានប្រគល់ឱ្យវិញទេ ហើយចំពោះផ្ទះដែល តុលាការរឹបអូសនោះខ្លួនស្នើសុំឱ្យតុលាការប្រគល់ឱ្យកូនក្តីវិញដោយសារក្តីខ្លួនបានយកទៅដាក់ធានាធនាគារចំនួនពីរនិងអម្រឹតមួយកន្លែងទៀត ដាក់ដើម្បីទិញផ្ទះនិងដីដែលគាត់រស់នៅមួយទៀតគឺស្នើសុំឱ្យតុលាការប្រគល់រថយន្តមួយគ្រឿងដែលសមត្ថកិច្ចចាប់ដកហូតមកឱ្យកូនក្តីខ្លួនវិញ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

លោកមេធាវី [redacted] យ៉េត ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] សុផល បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖តាមរយៈសវនាការនេះ ឃើញថាកូនក្តីខ្លួនបានទទួលស្គាល់ថានៅអ្វីដែលគាត់បានធ្វើនិងនៅអ្វីដែលគាត់មិនបានធ្វើ តែទោះជាយ៉ាងណាក៏ដោយចំណុចទាំងអស់នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិ ស្នើសុំឱ្យតុលាការពិចារណាសម្រេចក្តីដោយក្តីអនុគ្រោះផង គាត់ជាមន្ត្រីនគរបាលមិនធ្លាប់មានប្រវត្តិរកស៊ីជួញដូរគ្រឿងញៀនពីមុនទាល់តែសោះ ប៉ុន្តែអ្វីដែលកើតឡើងនៅពេលហ្នឹងដោយសារមានការញុះញង់ពីក្មួយដែលធ្វើឱ្យគាត់ខ្វះការពិចារណា ហើយម៉្យាងវិញទៀតគាត់ធ្លាប់ជួបគ្រោះចរាចរណ៍ប៉ះក្បាលផង ទើបធ្វើឱ្យការគិតរបស់គាត់មិនបានត្រឹមត្រូវ ធ្វើឱ្យគាត់ចូលរួមចំណែកការប្រព្រឹត្តបទល្មើសហេតុដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំឱ្យតុលាការពិចារណាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនដោយក្តីអនុគ្រោះផង។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

លោកមេធាវី [redacted] តាន់អៀម ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] បូរ៉ា បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ស្នើសុំឱ្យតុលាការសម្រេចតាមច្បាប់។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ៖

-ឈ្មោះ [redacted] សុផល បាននិយាយសម្តីចុងក្រោយបង្អស់ថា៖ ខ្លួនបានសុំឱ្យតុលាការសម្រេចបន្ធូរបន្ថយទោសក្តីអនុគ្រោះផង។

-ក្រោយពីបានសួរដេញដោលក្នុងអង្គសវនាការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ នៅចំណុចភូមិស្រែពោធិ៍ សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ពិតជាមានអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងកាន់កាប់ ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត មួយបានកើតឡើងប្រាកដមែន។

114
3

២-អំពើល្មើសខាងលើប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] បូរ៉ា ភេទប្រុស អាយុ៣២ឆ្នាំ ត្រូវជាក្មួយរបស់ឈ្មោះ [redacted] សុផល ភេទប្រុស អាយុ៤៥ឆ្នាំ បានមកប្រាប់ឈ្មោះ [redacted] សុផល ថាមានគេទៅប៉ោយប៉ែតជាថៅកែស៊ីម៉ង់ ឧស្សាហ៍ចេញប្រទេសថៃ មានគេចង់បានគ្រឿងញៀនប្រភេទគ្រាប់ ពេលនោះឈ្មោះ [redacted] សុផល បានប្រាប់ថាចាំខ្លួនទៅទំនាក់ទំនងគេឲ្យ។ ហើយនៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ វេលាម៉ោងប្រហែល០៧ព្រឹក ឈ្មោះ ភ័ក្ត្រ បានតេទូរស័ព្ទមកឈ្មោះ [redacted] សុផល ម៉ោង ១០ព្រឹកនេះ គេមកយកឥវ៉ាន់(ថ្នាំញៀន) ហើយ ពេលនោះឈ្មោះ [redacted] សុផល បានយកគ្រឿងញៀនដាក់ក្នុងឡានរួចបើកឡានចេញពីចំការមកក្រៅ បានឈប់ឡានប្រហែល១៥ម៉ែត្រ ពីឡានអ្នកទិញ ហើយឈ្មោះ ភ័ក្ត្រ ក៏បានចូលទៅក្នុងឡានរបស់ឈ្មោះ [redacted] សុផល រួចក៏បានយកគ្រឿងញៀនទៅចូលក្នុងឡានរបស់អ្នកទិញ ប្រហែល១៥នាទី ក្រោយមកមានមនុស្សម្នាក់ចេញពីឡានព្រុសមកបាញ់បំបែកកង់ឡានរបស់ឈ្មោះ [redacted] សុផល ផ្នែកខាងឆ្វេង ហើយភ្ជង់ឈ្មោះ [redacted] សុផល ឲ្យក្រាបទៅនឹងដី រួចក៏បានធ្វើការចាប់ឃាត់ខ្លួន ឆែកឆេរនិងធ្វើការដកហូតវត្ថុតាងមានថ្នាំញៀនប្រភេទមេតំហ្វេតាមីន (WY) ចំនួន ២៤000 គ្រាប់ ទម្ងន់សរុប២.១៣៤,៥ក្រាម រួចបញ្ជូនមកការិយាល័យប្រឆាំងគ្រឿងញៀន ដើម្បីធ្វើការសាកសួរ និងចាត់ការតាមនីតិវិធីច្បាប់តែម្តង។

៣-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុផល នៅពេលសវនាការបានឆ្លើយថា៖ ខ្លួនដឹងបទចោទហើយ គឺបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងកាន់កាប់ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត។ ចំពោះបទចោទនេះខ្លួនសុំបដិសេធ ពីព្រោះខ្លួនមិនបានប្រព្រឹត្តដូចតំណាងអយ្យការចោទឡើយ។ ខ្លួនធ្វើការជាប៉ូលីសខេត្តស្ទឹងត្រែងមែន ហើយអង្គហេតុឈ្មោះ [redacted] បូរ៉ា បានប្រាប់ថាគេចង់បានគ្រឿងញៀនខ្លួនទទួលស្គាល់ ប៉ុន្តែខ្លួនមិនបានរកថ្នាំញៀនឲ្យឈ្មោះ [redacted] បូរ៉ា ទេ រីឯឈ្មោះឈ្មោះ វិល័យ នៅប្រទេសឡាវ ខ្លួនធ្លាប់ស្គាល់ដែរ។ ចំពោះស្បោងថង់នេះខ្លួនជាអ្នកយួរស្បោងនេះមកដាក់ឡានមែន ប៉ុន្តែខ្លួនមិនបានដឹងថាក្នុងស្បោងនេះមានថ្នាំញៀនទេ បើដឹងថាក្នុងថង់នោះមានថ្នាំញៀនក៏ខ្លួនមិនយួរមកដាក់ឡានដែរ។ មូលហេតុដែលខ្លួនទៅចំការនេះ ពីព្រោះចំការនេះជារបស់ខ្លួនទុកសម្រាប់ចិញ្ចឹមត្រី។ ចំពោះស្បោងថង់នេះពេលដែលខ្លួនយកមកគ្មានអ្វីទេ។ នៅពេលនោះមានឡានព្រុសមួយចេញមកបាញ់កង់ឡានខ្លួនរួចភ្ជង់ខ្លួនឲ្យក្រាបចុះស្រាប់តែងើបឡើងថាថង់នេះជារបស់ខ្លួនមានថ្នាំញៀនទៅវិញ។ នៅពេលដែលសមត្ថកិច្ចចាប់ឃាត់រូបខ្លួនឈ្មោះ ភ័ក្ត្រ ក៏រត់ទៅបាត់មិនដឹងទៅណាទេ។ ខ្លួននិងឈ្មោះ ភ័ក្ត្រ ត្រូវជាពូនិងក្មួយ។ ខ្លួនមានអាវុធម៉ាក k៥៩ មានលិខិតប្រើប្រាស់ស្របច្បាប់។ នៅសមត្ថកិច្ចតំណាងអយ្យការនិងនៅក្រមស៊ើបសួរ ខ្លួនសុំមិនទទួលស្គាល់ទេសុំបដិសេធ។ ខ្លួនសុំបញ្ជាក់ថា ថង់នេះមិនមែនពណ៌ខ្មៅទេ គឺពណ៌ទឹកក្រូច ចំពោះថង់នេះឈ្មោះ ភ័ក្ត្រ បានប្រើខ្លួនឲ្យជួយយកឲ្យវាមែន។ ការសាកសួរ នៅដំណាក់កាលសមត្ថកិច្ច ,តំណាងអយ្យការ,នៅចៅក្រមស៊ើបសួរពុំមានពីណាបង្ខិតបង្ខំឲ្យឆ្លើយឡើយ។ ខ្លួនសុំបដិសេធថាមិន បានចូលរួមប្រព្រឹត្តបទល្មើសជាមួយឈ្មោះ ភ័ក្ត្រ ទេ។ នៅពេលខ្លួនឆ្លើយសារភាពថា៖ ចំពោះអង្គហេតុជួញដូរថ្នាំញៀនខ្លួនពិតជាបានប្រព្រឹត្តមែន។ ប៉ុន្តែខ្លួនមិនបានដឹងថាថ្នាំញៀនមានក្នុងថង់នោះទេ។

ចម្លើយនេះតុលាការយល់ឃើញថា ការឆ្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សុផល ហាក់ដូចជាមិនច្បាស់លាស់ដដែល ប៉ុន្តែជនជាប់ចោទឈ្មោះ [redacted] សុផល បានឆ្លើយសារភាពនៅចំពោះមុខចៅក្រមស៊ើបសួរខេត្តស្ទឹងត្រែងថា ឈ្មោះ [redacted] បូរ៉ា ភេទប្រុស អាយុ៣២ឆ្នាំ ត្រូវជាក្មួយរបស់ខ្លួន បានមកប្រាប់ខ្លួន ថាមានគេនៅប៉ោយប៉ែតជាថៅកែស៊ីម៉ង់ ឧស្សាហ៍ចេញចូលប្រទេសថៃ គេមានបំណងចង់បានគ្រឿងញៀនប្រភេទគ្រាប់ ពេលនោះឈ្មោះ [redacted] សុផល បានប្រាប់ថាចាំខ្លួនទៅទំនាក់ទំនងគេឲ្យ។ ហើយនៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ វេលាម៉ោងប្រហែល០៧ព្រឹក ឈ្មោះ ភ័ក្ត្រ បានតេទូរស័ព្ទមកឈ្មោះ [redacted] សុផល ម៉ោង១០ព្រឹកនេះ គេមកយកឥវ៉ាន់(ថ្នាំញៀន) ហើយពេលនោះឈ្មោះ [redacted] សុផល បានយកគ្រឿងញៀនដាក់ក្នុងឡានរួចបើកឡានចេញពីចំការហើយក៏ បានឈប់ឡានប្រហែល១៥ម៉ែត្រ ពីឡានអ្នកទិញហើយឈ្មោះ ភ័ក្ត្រ ក៏បានចូលទៅក្នុងឡានរបស់ឈ្មោះ [redacted] សុផល រួចក៏បានយកគ្រឿងញៀនចូលទៅក្នុងឡានរបស់អ្នកទិញ ប្រហែល១៥នាទី ក្រោយមកមានមនុស្ស

114/2

ម្នាក់ចេញពីឡានព្រុសមកបាញ់បំបែកកង់ឡានរបស់ឈ្មោះ [redacted] សុផល ផ្នែកខាងឆ្វេង ហើយក៏បានធ្វើការចាប់ឃាត់ខ្លួនឈ្មោះ [redacted] សុផល បានធ្វើការរកឃើញវត្ថុតាងមានថ្នាំញៀនប្រភេទមេតំហ្វេតាមីន (WY) ចំនួន ២៤០០០ គ្រាប់ ទម្ងន់សរុប២.១៣៤,៥ ក្រាម។ ដូច្នេះចម្លើយនេះពិតជាមានភាពស៊ីសង្វាក់ ទៅនឹងអង្គហេតុដែលបានកើតឡើង ជាពិសេសស៊ីសង្វាក់ទៅនឹងអង្គហេតុនៃការចោទប្រកាន់របស់តំណាងអយ្យការប្រាកដមែន។

៦-ជនជាប់ចោទឈ្មោះ [redacted] បូរ៉ា ក្រោយពីបានប្រព្រឹត្តបទល្មើសរួចក៏បានគេចខ្លួនគ្រប់តំណាក់កាលនីតិវិធីចំណុចនេះគប្បីតុលាការពិចារណា។

៧-ជនជាប់ចោទទាំងពីពិតជាចារីដែលបានប្រព្រឹត្តអំពើទុច្ចរិត ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងកាន់កាប់ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀននិងមាត្រា ៤៩០នៃក្រមព្រហ្មទណ្ឌប្រាកដមែន។

៨-អំពើ និងសកម្មភាពរបស់ជនជាប់ចោទទាំងពីរធ្វើអោយខូចសណ្ដាប់ធ្នាប់របៀបរៀបរយសាធារណៈ ដែលច្បាប់បានការពារ និងតម្រូវឱ្យផ្ដន្ទាទោស។

៩-ពេលធ្វើសកម្មភាពជនជាប់ចោទទាំងពីរមានសតិបញ្ញាស្មារតីគ្រប់គ្រាន់ ប្រព្រឹត្តអំពើល្មើសច្បាប់រហូតសម្រេចតាមបំណងរបស់ខ្លួន។

១០-តំណាងអយ្យការប្ដឹងសុំឱ្យតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ ដែលចំណុចនេះគប្បីតុលាការពិចារណា។

១១-តាមលទ្ធផលនៃការគណនាអំពីវត្ថុចាប់យក ជាសារធាតុញៀនរបស់ជនជាប់ចោទប្រភេទម្សៅឈ្មោះ មេតំហ្វេតាមីន (Methamphetamine) មានទម្ងន់ ២១៣៤,៥ ក្រាម គុណ ១៥,១២ ចែក ១០០ ស្មើ ៣២២,៧៨ ក្រាម។

តាមលទ្ធផល ៣២២,៧៨ ក្រាម គឺវាស្ថិតនៅក្នុងតារាងទី២ នៃមាត្រា ៤០ កថាខណ្ឌទី៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ដែលតម្រូវឱ្យផ្ដន្ទាទោសពី ២០ឆ្នាំ ទៅ ៣០ឆ្នាំ ឬអស់មួយជីវិត និងផ្ដន្ទាទោសពិន័យជាប្រាក់ពី ៤០.០០០.០០០ (សែសិបលាន)រៀល ទៅ ១០០.០០០.០០០(មួយរយលាន)រៀល ។

១២-ចំពោះទ្រព្យសម្បត្តិរបស់ជនជាប់ចោទឈ្មោះ ឯម សុផល ដូចមាននៅក្នុងពាក្យសុំបើកធ្វើសកម្មភាព ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០១៧ និងដីកាសម្រេចមិនព្រមបើកឲ្យធ្វើសកម្មភាពរបស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ លេខ:៣០២ ឈ.ព្រ.ទ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ នោះ ក្រុមប្រឹក្សាយល់ឃើញថាផ្អែកតាមមាត្រា៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការមានសមត្ថកិច្ចសម្រេចអំពីការប្រគល់វត្ថុដែលចាប់យកបាន ក៏ប៉ុន្តែដោយយោងមាត្រា៦២នៃក្រមព្រហ្មទណ្ឌ ទ្រព្យសម្បត្តិដែលអាចរឹបអូសបានទាល់តែសម្បត្តិនោះ គឺជាផលទុនឬទ្រព្យសម្បត្តិដែលជាផលនៃបទល្មើស។ ដូច្នេះឃើញថាទ្រព្យសម្បត្តិទាំងនេះ តុលាការពុំអាចកំណត់បានថាជាផលទុនឬទ្រព្យសម្បត្តិដែលកើតចេញពីបទល្មើសនៅឡើយ ហេតុនេះគប្បីតុលាការមិនពិចារណាសម្រេចអំពីទ្រព្យសម្បត្តិទាំងនោះឡើយ គឺទុកសមត្ថកិច្ចជូនតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ធ្វើចំណាត់ការទៅតាមនីតិវិធីច្បាប់។ រីឯវត្ថុចាប់យកចំនួនដែលបានប្រើប្រាស់និងបំរើឲ្យការប្រព្រឹត្តបទល្មើសនោះ តុលាការនិងធ្វើការពិចារណាសម្រេចរឹបអូសទៅតាមច្បាប់។

១៣-វត្ថុចាប់យករួមមាន៖ប្រអប់ដែករាងជ្រុងចំនួនមួយ ដាក់គ្រឿងញៀនប្រភេទមេតំហ្វេតាមីនទម្ងន់ ២១៣៤,៥ក្រាម (ពីរពាន់មួយរយសាមសិបបួនក្បៀសប្រាំក្រាម)ស្មើនឹង២៤០០០គ្រាប់,សំបកកេះបួនជ្រុង មានអក្សរSMART ពណ៌ខ្មៅលាយពណ៌បៃតងខ្ចីចំនួនមួយ,ថង់ពណ៌ខៀវតូចៗចំនួនមួយ និងទូរស័ព្ទម៉ាកណូគា ចុចពិល ពណ៌ខ្មៅ ចំនួនមួយគ្រឿង ដែលវត្ថុទាំងនេះជាវត្ថុដែលមានទំនាក់ទំនងនិងបំរើឲ្យ សកម្មភាពប្រព្រឹត្តបទល្មើសគប្បីតុលាការសម្រេចរឹបអូស។

១៤-មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ ឯម សុផល ភេទប្រុស អាយុ ៤៥ឆ្នាំ សញ្ជាតិខ្មែរ ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងកាន់កាប់ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុច

ភូមិស្រែពោធិ៍ សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ។

១៥-មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] បូរ៉ា ហៅភ័ក្រ្ត ភេទប្រុស អាយុប្រហែល ៣០ឆ្នាំ សញ្ជាតិខ្មែរ ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច ភូមិស្រែពោធិ៍ សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង កាលពីថ្ងៃទី០៨ខែកុម្ភៈ ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៤០នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## ហេតុដូច្នេះ សម្រេច

១-ផ្តន្ទាទោសលើឈ្មោះ ៖

ក.[redacted] សុផល ភេទប្រុស អាយុ ៤៥ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២៥ ឆ្នាំ (ម្ភៃប្រាំឆ្នាំ) ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងកាន់កាប់ឬដឹកជញ្ជូនអាវុធ ដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅចំណុច ភូមិស្រែពោធិ៍ សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៤៩០ នៃ ក្រមព្រហ្មទណ្ឌ។

ខ.[redacted] បូរ៉ា ហៅ ភ័ក្រ្ត ភេទប្រុស អាយុប្រហែល ៣០ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២៥ ឆ្នាំ (ម្ភៃប្រាំឆ្នាំ) ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច ភូមិស្រែពោធិ៍ សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-បង្គាប់ឱ្យចាប់ខ្លួន-ឃុំខ្លួនឈ្មោះ [redacted] បូរ៉ា ហៅ ភ័ក្រ្ត ដែលមានអត្តសញ្ញាណខាងលើដោយអនុវត្តតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-បញ្ឈប់អនុភាពនៃដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ: ០១១ ពស ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តស្ទឹងត្រែង ។

៤-វត្ថុចាប់យកដែលត្រូវរឹបអូសមាន ៖

ក.ប្រអប់ដែករាងជ្រុងចំនួនមួយ ដាក់គ្រឿងញៀនប្រភេទមេតំហ្វេតាមីន ទម្ងន់ ២១៣៤,៥ក្រាម (ពីរពាន់មួយរយសាមសិបបួនក្បៀសប្រាំក្រាម) ស្មើនឹង ២៤០០០ គ្រាប់ ។

ខ.សំបកកេះបួនជ្រុង មានអក្សរ SMART ពណ៌ខ្មៅលាយពណ៌បៃតងខ្ចី ចំនួនមួយ ។

គ.ថង់ពណ៌ខៀវតូចៗចំនួនមួយ។

ឃ. ទូរស័ព្ទម៉ាកណូគា ចុចពិល ពណ៌ខ្មៅ ចំនួនមួយគ្រឿង។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ ឯម សុផល កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] បូរ៉ា ហៅ ភ័ក្រ្ត មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ ។

ភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់បានកំណត់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |

“បានចម្លងត្រឹមត្រូវតាមច្បាប់ដើម”

ថ្ងៃសុក្រ ៨រោច ខែមាឃ ឆ្នាំរកា នព្វស័ក ពស២៥៦១

[illegible] ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៨

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]